ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ
# ស្តីពី
# ការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី
# សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
# ឆ្នាំ២០២៤-២០២៨



ក្រសួងមហាផ្ទៃ

១៦ កុម្ភៈ ២០២៤

# អារម្ភកថា

បន្ទាប់ពីការបញ្ចប់ដោយជោគជ័យនូវការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញ **យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១សម្រាប់កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយផ្តោតលើវិស័យអាទិភាពចំនួន៥ គឺ**មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា** ដើម្បីបន្តកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ជាប្រទេសមានចំណូលខ្ពស់។

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១នេះ គឺជាមគ្គុទេសក៍សម្រាប់តម្រង់ទិសដល់ការរៀបចំ និងអនុវត្តសកម្មភាពអាទិភាពនានារបស់ក្រសួង ស្ថាប័ន និងតួអង្គពាក់ព័ន្ធ ក្នុងគោលដៅបន្តរក្សាឱ្យបានរឹងមាំនូវសុខសន្តិភាព ពង្រឹងសមិទ្ធផលនៃកិច្ចអភិវឌ្ឍដែលសម្រេចបាននាពេលកន្លងមក ព្រមទាំងកសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសន្ទុះនៃការអភិវឌ្ឍប្រទេសជាតិក្នុងរយៈពេលមធ្យម និងរយៈពេលវែង។

ក្រសួងមហាផ្ទៃ ដែលជាស្ថាប័នឆ្អឹងខ្នងដ៏សំខាន់មួយ ដើរតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់លើវិស័យនយោបាយរដ្ឋបាល និងដឹកនាំគ្រប់គ្រងនគរបាល ជាតិលើវិស័យសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវឈានមុខក្នុងការដឹកនាំ រៀបចំ និងអនុវត្តគោលនយោបាយអាទិភាព និងវិធានការគន្លឹះនានាពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។

ក្នុងន័យនេះ ដើម្បីធានាដល់ការបំពេញតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្រសួងមហាផ្ទៃបានរៀបចំផែនការយុទ្ធសាស្ត្រស្តីពី "**ការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**" ធ្វើជាផែនទីបង្ហាញផ្លូវច្បាស់លាស់មួយសម្រាប់អនុវត្តពីឆ្នាំ២០២៤ដល់ឆ្នាំ២០២៨ សំដៅចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ឱ្យសម្រេចបានគោលដៅ គោលបំណង និងចក្ខុវិស័យដែលបានកំណត់។

ផែនការយុទ្ធសាស្ត្រស្តីពី "**ការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**"នេះ បានរៀបចំឡើងដោយមានការសិក្សា

ស្រាវជ្រាវលើឯកសារពាក់ព័ន្ធនានា ជាពិសេសច្បាប់ លិខិតបទដ្ឋានគតិយុត្ត កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងសមត្ថកិច្ច តួនាទី ភារកិច្ចរបស់ក្រសួងមហាផ្ទៃ កម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាល ព្រមទាំងមានការពិគ្រោះយោបល់ ការប្រមូលធាតុចូលពីគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ចំណុះក្រសួងមហាផ្ទៃ។

ផែនការយុទ្ធសាស្ត្រនេះ បានកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រច្បាស់លាស់ដែលក្រសួងមហាផ្ទៃចាំបាច់ត្រូវចូលរួមអនុវត្តគោលនយោបាយអាទិភាព និងវិធានការគន្លឹះនានាដែលបានកំណត់នៅក្នុងទិដ្ឋភាពធំៗទាំង៣នៃយុទ្ធសាស្ត្របញ្ចកោណ គឺ (ទី១)-**ស្នូលនៃយុទ្ធសាស្ត្រ** គឺការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច (ទី២)-**បរិស្ថានគ្រប់ដណ្ដប់**សម្រាប់ធានាបរិយាកាសអំណោយផលដល់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល និង(ទី៣)-**បញ្ចកោណយុទ្ធសាស្ត្រទាំង៥** សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម។

ផែនការយុទ្ធសាស្ត្រនេះ បានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗចំនួន៦ ដោយផ្ដោតលើបណ្ដុំការងារ ឬចង្កោមសកម្មភាពធំៗដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ រួមមាន (១)ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ (២)ការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម (៣)ការលើកកម្ពស់ការគ្រប់គ្រងពន្ធនាគារ (៤)ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្សក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ (៥)ការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ និង(៦)ការងារបច្ចេកវិទ្យាឌីជីថល។ យុទ្ធសាស្ត្រនីមួយៗបានកំណត់នូវសកម្មភាពជាអាទិភាពសំខាន់ៗ ដែលត្រូវរៀបចំ និងអនុវត្តដោយអង្គភាពពាក់ព័ន្ធនានាចំណុះក្រសួងមហាផ្ទៃ ដើម្បីធានាដល់ការសម្រេចបានគោលដៅ គោលបំណង និងចក្ខុវិស័យនៃផែនការយុទ្ធសាស្ត្រនេះ។ ក្រៅពីនេះ ផែនការយុទ្ធសាស្ត្រក៏បានកំណត់នូវយន្តការដឹកនាំ គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃដោយបានកំណត់នូវសូចនាករ និងចំណុចដៅសំខាន់ៗដែលជាមូលដ្ឋានសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើសមិទ្ធផល និងប្រសិទ្ធភាពនៃការបំពេញបេសកកម្មរបស់ក្រសួងមហាផ្ទៃក្នុងនីតិកាលទី៧នៃរដ្ឋសភា។

ក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ សមាជិក សមាជិកានៃគណៈកម្មការចំពោះកិច្ចក្រុមការងារបច្ចេកទេស និងមន្ត្រីនៃអង្គភាពពាក់ព័ន្ធនានាដែលបានខិតខំដឹកនាំ សម្របសម្រួលសហការគ្នាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រស្ដីពី "**ការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដីសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**" ដ៏មានសារៈសំខាន់នេះ។

ខ្ញុំសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារដែលបម្រើការងារនៅតាមអង្គភាពនានាចំណុះក្រសួងមហាផ្ទៃនឹងបន្តរួមសាមគ្គីគ្នា និងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពី "**ការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**" នេះឱ្យទទួលបានជោគជ័យតាមការរំពឹងទុក។

ថ្ងៃ..សុក្រ..៧កើត..ខែ..មាឃ..... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៦....ខែ..កុម្ភៈ......ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

# មាតិកា


អារម្ភកថា ..................................................................................... i

មាតិកា ......................................................................................... iv

១. សេចក្តីផ្តើម ................................................................................. 1

២. ចក្ខុវិស័យ ................................................................................... 5

៣. គោលបំណង និងគោលដៅ ................................................................. 7

៣.១. គោលបំណង ............................................................................. 7

៣.២. គោលដៅ .................................................................................. 7

៤. គោលការណ៍ជាមូលដ្ឋាន ................................................................... 8

៥. យុទ្ធសាស្ត្រ ................................................................................... 9

យុទ្ធសាស្ត្រទី១៖ ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ................................. 9

យុទ្ធសាស្ត្រទី២៖ ការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ សណ្តាប់ធ្នាប់ សាធារណៈ និងសុវត្ថិភាពសង្គម ............................................ 11

យុទ្ធសាស្ត្រទី៣៖ ការលើកកម្ពស់ការគ្រប់គ្រងពន្ធនាគារ ...................................... 14

យុទ្ធសាស្ត្រទី៤៖ ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស ..................................... 15

យុទ្ធសាស្ត្រទី៥៖ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ 18

យុទ្ធសាស្ត្រទី៦៖ ការងារបច្ចេកវិទ្យាឌីជីថល ................................................... 20

៦. ការគ្រប់គ្រងការអនុវត្ត ........ 22

៧. គម្រោងថវិកា ........ 23

៨. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ ........ 24

៨.១. ការរៀបចំទិន្នន័យដើមគ្រា ........ 24

៨.២. ការតាមដានត្រួតពិនិត្យ ........ 25

៨.៣. ការវាយតម្លៃប្រចាំឆ្នាំ ........ 25

៨.៤. ការវាយតម្លៃចុងបញ្ចប់នៃផែនការយុទ្ធសាស្ត្រ ........ 26

៩. សេចក្តីសន្និដ្ឋាន ........ 26

ឧបសម្ព័ន្ធ៖ តារាងសូចនាកររួម ........ 28

## ១. សេចក្តីផ្តើម

ក្រសួងមហាផ្ទៃមានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់លើវិស័យនយោបាយរដ្ឋបាល និងការដឹកនាំគ្រប់គ្រងនគរបាលជាតិលើវិស័យសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងមហាផ្ទៃមានកាតព្វកិច្ចចាត់វិធានការអនុវត្តសកម្មភាពនានាដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ កម្មវិធីនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល តាមអាណត្តិនីមួយៗ។

ក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលអាណត្តិទី៦(២០១៨-២០២៣) ទោះបីប្រទេសកម្ពុជាបានទទួលរងនូវឥទ្ធិពលពីវិបត្តិសកលជាច្រើន ដូចជាការផ្ទុះឡើងនូវជំងឺកូវីដ-១៩ ជម្លោះនិងសង្គ្រាមដែលកើតឡើងពីការប្រកួតប្រជែងផលប្រយោជន៍សេដ្ឋកិច្ច ការដណ្តើមភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាចដែលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលដល់សន្តិសុខជាតិ សុវត្ថិភាពសង្គម និងសេដ្ឋកិច្ចជាតិ រួមទាំងការប៉ុនប៉ងបង្កឱ្យមានអស្ថិរភាពនយោបាយរបស់ក្រុមប្រឆាំងជ្រុលនិយមក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ក៏ក្រសួងមហាផ្ទៃ ក្រោមការដឹកនាំប្រកបដោយឆន្ទៈម៉ឺងម៉ាត់ តម្កល់ផលប្រយោជន៍ជាតិ និងប្រជាជនជាធំរបស់ **សម្តេចក្រឡាហោម ស ខេង** ដោយមានការចូលរួមសហការ និងការគាំទ្រពីក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងសាធារណជនបានជម្នះរាល់ឧបសគ្គ ព្រមទាំងធ្វើឱ្យសម្រេចនូវសមិទ្ធផលជាច្រើនទាំងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងរដ្ឋបាលដែនដី និងការគ្រប់គ្រងនគរបាលជាតិ។

ក្រសួងមហាផ្ទៃបានចូលរួមយ៉ាងសកម្មក្នុងការថែរក្សាការពារបានយ៉ាងល្អប្រសើរនូវសន្តិភាព ស្ថិរភាពនយោបាយ បូរណភាពទឹកដី អធិបតេយ្យភាពជាតិ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដែលជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ធានាដល់ការរស់នៅប្រកបដោយភាពសុខសាន្តរបស់ប្រជាជន

ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ សុវត្ថិភាពព្រះមហាក្សត្រ និងឥស្សរជនថ្នាក់ដឹកនាំប្រទេស ព្រមទាំងការរៀបចំព្រឹត្តិការណ៍នយោបាយជាតិ និងអន្តរជាតិសំខាន់ៗនៅកម្ពុជាឱ្យប្រព្រឹត្តទៅដោយរលូន ជោគជ័យ និងមោទនភាពជាតិ។

គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការបង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ សកម្មភាពក្មេងទំនើង ការអនុវត្តច្បាប់ចរាចរណ៍ ការផ្តល់អន្តរាគមន៍ពន្លត់អគ្គីភ័យ និងការសង្គ្រោះជនរងគ្រោះនានាត្រូវបានជំរុញ និងពង្រឹងការអនុវត្តជាប្រចាំដែលធានាបាននូវប្រក្រតីភាពនៃការរស់នៅរបស់ប្រជាជនប្រកបដោយភាពសុខសាន្ត។ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មត្រូវបានពង្រឹងទាំងក្នុងក្របខ័ណ្ឌនៃការរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងការផ្តល់សេវាអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មជូនប្រជាជន ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបមានអត្តសញ្ញាណខាងផ្លូវច្បាប់ពេញលេញ ធានាបាននូវការគោរពសិទ្ធិមនុស្ស និងទទួលបានសេវាជាមូលដ្ឋានចាំបាច់នានាស្របតាមច្បាប់។ ការងារអន្តោប្រវេសន៍ក៏ត្រូវបានជំរុញការអនុវត្ត និងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដោយធានាបានយ៉ាងគត់មត់នូវអធិបតេយ្យភាពជាតិ ការទប់ស្កាត់មិនឱ្យកើតមានឡើងនូវអំពើភេរវកម្មនៅកម្ពុជា ការលួចលាក់ជ្រកកោនធ្វើសកម្មភាពរបស់អង្គការភេរវកម្មនានា ការជ្រៀតចូល និងស្នាក់នៅដោយខុសច្បាប់របស់ជនបរទេសអន្តោប្រវេសន៍ ការគ្រប់គ្រងដំណើរចេញចូលប្រទេសដែលកិច្ចការទាំងនេះឆ្លើយតបជាវិជ្ជមានចំពោះនយោបាយទេសចរណ៍ជាតិ ការវិនិយោគ ពាណិជ្ជកម្ម ការអភិវឌ្ឍវិស័យការងារ និងវិស័យពាក់ព័ន្ធផ្សេងទៀត។ ពាក់ព័ន្ធនឹងការងារគ្រប់គ្រងច្រកទ្វារព្រំដែន ក្រសួងមហាផ្ទៃបានសហការជាមួយអាជ្ញាធរ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការដឹកនាំ សម្របសម្រួល គ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំលើសកម្មភាពនានានៅតាមច្រកទ្វារព្រំដែន ដោយធានាបាននូវប្រក្រតីភាព និងសុវត្ថិភាពនៃការធ្វើដំណើរការចេញចូល និងទំនាក់ទំនងពាណិជ្ជកម្មស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក៏មានវឌ្ឍនភាពយ៉ាងល្អប្រសើរ ជាពិសេសការរៀបចំកែលម្អរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង

និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរសិទ្ធិអំណាច មុខងារ ធនធាន និងការទទួលខុសត្រូវកាន់តែច្រើនឡើងៗជាបន្តបន្ទាប់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមកម្រិតថ្នាក់នីមួយៗកាន់តែមានសមត្ថភាព លទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការជំរុញ និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមមូលដ្ឋាន និងការផ្តល់សេវាសាធារណៈឆ្លើយតបទៅនឹងតម្រូវការ និងការដោះស្រាយបញ្ហាប្រឈមរបស់ប្រជាជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយភាពម្ចាស់ការខ្ពស់ ចំគោលដៅ ទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព យុត្តិធម៌ បរិយាបន្ន និងសមធម៌សង្គម។

ក្រៅពីសមិទ្ធផលសំខាន់ៗខាងលើនេះ ក៏មានសមិទ្ធផលនានាជាច្រើនទៀតដែលក្រសួងមហាផ្ទៃបានខិតខំសម្រេចបានក្នុងរយៈពេល៥ឆ្នាំ នៃអាណត្តិទី៦របស់រាជរដ្ឋាភិបាលកន្លងមកនេះ រួមមានដូចជា ការរៀបចំក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងពន្ធនាគារ ការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ការចុះធ្វើអធិការកិច្ច ការបង្កើតយន្តការទទួល និងដោះស្រាយបណ្តឹងតវ៉ា ការទទួលមតិយោបល់ និងការដោះស្រាយសំណើសំណូមពររបស់ប្រជាជនជាដើម។

ជារួម សមិទ្ធផលដែលក្រសួងមហាផ្ទៃសម្រេចបានទាំងនេះ បានរួមចំណែកដ៏ធំធេងធ្វើឱ្យរាជរដ្ឋាភិបាលអាណត្តិទី៦សម្រេចបាននូវសមិទ្ធផលធំៗជាច្រើនក្នុងការកសាង ការការពារសុខសន្តិភាព ការការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី និងការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យឱ្យមានការរីកចម្រើនជាបន្តបន្ទាប់ជូនជាតិមាតុភូមិ និងប្រជាជន។

ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលគួរជាទីមោទនភាពទាំងនេះ ក៏នៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលត្រូវបន្តការដោះស្រាយដោយស្មារតីប្រុងប្រយ័ត្នខ្ពស់។ សភាពការណ៍នយោបាយ សន្តិសុខសង្គ្រាម និងជម្លោះរវាងបណ្តាប្រទេសនានាក្នុងតំបន់ និងនៅលើសកលលោកបាន និងកំពុងបន្តការវិវឌ្ឍប្រែប្រួលរាលដាលកាន់តែស្មុគស្មាញ និងពិបាកប៉ាន់ស្មាន។ សភាពការណ៍ទាំងនេះអាចបន្តជះឥទ្ធិពល

មិនល្អមកលើសន្តិសុខជាតិ សុវត្ថិភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ប្រការនេះ តម្រូវឱ្យអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចត្រូវបន្តខិតខំពង្រឹងការតាមដានវាយតម្លៃសភាពការណ៍ឱ្យបានល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយ ដើម្បីធានាដល់ការចាត់វិធានគ្រប់គ្រងសភាពការណ៍ទាំងនេះឱ្យបានល្អប្រសើរ ធានាដល់ការដោះស្រាយបញ្ហា និងកាត់បន្ថយនូវហានិភ័យនានាដែលអាចកើតឡើងជាយថាហេតុឱ្យស្ថិតក្នុងស្ថានភាពដែលរាជរដ្ឋាភិបាលអាចគ្រប់គ្រងបាន។

ការកើនឡើងនូវសកម្មភាពផលិត ការធ្វើចរាចរ ការជួញដូរ ការប្រើប្រាស់គ្រឿងញៀនក្នុងតំបន់ និងពិភពលោកក៏បានធ្វើឱ្យមានកំណើននូវសកម្មភាពគ្រឿងញៀនខុសច្បាប់ក្នុងប្រទេសកម្ពុជា ក្នុងនោះរួមទាំងការលួចលាក់ប្រើប្រាស់សារធាតុគីមីនាំចូល ការកែច្នៃផលិតគ្រឿងញៀនខុសច្បាប់ដែលបញ្ហានេះមិនត្រឹមតែមានផលប៉ះពាល់មកលើសុខុមាលភាព និងជីវភាពប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែក៏អាចបង្កឱ្យមានបទល្មើសក្នុងសង្គមកាន់តែស្មុគស្មាញថែមទៀតផងដែរ។ ករណីគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលឱ្យមនុស្សស្លាប់ រងរបួស និងខាតបង់ធនធានសង្គមជារៀងរាល់ថ្ងៃក៏នៅមិនទាន់ត្រូវបានកាត់បន្ថយឱ្យដល់កម្រិតអប្បបរមានៅឡើយ។ ប្រការនេះទាមទារនូវការបន្តជំរុញ និងពង្រឹងការចាត់វិធានការអនុវត្តច្បាប់ចរាចរណ៍ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

កម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៣-២០២៨) របស់រាជរដ្ឋាភិបាលអាណត្តិទី៧ ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) រួមជាមួយនឹងមេរៀន និងបទពិសោធន៍ល្អៗដែលក្រសួងមហាផ្ទៃធ្លាប់បានអនុវត្តនាពេលកន្លងមក គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់តម្រង់ទិសដល់ក្រសួងមហាផ្ទៃក្នុងការបំពេញតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល ដើម្បីធានាដល់ការបន្តរក្សាឱ្យបានរឹងមាំនូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ព្រមទាំងការពង្រឹងសមិទ្ធផលនៃការអភិវឌ្ឍ

ដែលសម្រេចបាននាពេលកន្លងមក ដើម្បីបន្តកសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសន្ទុះនៃការអភិវឌ្ឍប្រទេសជាតិក្នុងរយៈពេលមធ្យម និងរយៈពេលវែងរបស់កម្ពុជាស្របតាមចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ក្នុងន័យនេះ ដើម្បីធានាដល់ការចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឱ្យបានសម្រេចតាមគោលបំណងដែលបានរំពឹងទុក ក្រសួងមហាផ្ទៃចាំបាច់ត្រូវរៀបចំផែនការយុទ្ធសាស្ត្រដ៏ច្បាស់លាស់មួយ ធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់តម្រង់ទិសដល់ការដឹកនាំ ការគ្រប់គ្រង និងការអនុវត្ត តួនាទី ភារកិច្ច និងការទទួលខុសត្រូវក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពស្របតាមជាអាទិភាព និងវិធានការជាគន្លឹះនានាដែលបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។

## ២. ចក្ខុវិស័យ

ចក្ខុវិស័យរបស់ក្រសួងមហាផ្ទៃគឺ " **រដ្ឋបាលដែនដីនៅគ្រប់ថ្នាក់ ជារដ្ឋបាលរបស់ប្រជាជន កើតចេញពីប្រជាជន បម្រើសេវានិងផលប្រយោជន៍ប្រជាជន តាមគោលការណ៍អភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប្រទេសជាតិមានសុខសន្តិភាព សន្តិសុខ មានសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដែលជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ប្រជាជនមានសិទ្ធិសេរីភាព មានជីវភាពរស់នៅល្អប្រសើរ និងការរស់នៅប្រកបដោយភាពសុខក្សេមក្សាន្ត** "។

ការសម្រេចបាននូវចក្ខុវិស័យខាងលើនេះនឹងចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យកម្ពុជា ប្រែក្លាយកម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងសំដៅកសាងកម្ពុជាឱ្យក្លាយជាអរិយប្រទេសមួយនៅឆ្នាំ២០៥០ ដែលឆ្លើយតបនឹងលក្ខណៈសម្បត្តិដូចខាងក្រោម៖

១. កម្ពុជា ជា "**សង្គមជាតិមួយដ៏រស់រវើក**" ដែលមានសុខសន្តិភាពឋិតថេរចីរកាល មានស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈមាំមួន មានការគោរពច្បាប់ និងនីតិរដ្ឋពេញលេញ មានយុត្តិធម៌សង្គម និងមានការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជារដ្ឋរឹងប៉ឹងដែលមានឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី

ពេញលេញ មានភាពជាម្ចាស់រឹងមាំ មានអត្តសញ្ញាណជាតិជាក់លាក់ មានកិត្យានុភាព ខ្ពស់ត្រដែត និងស្មើភាព និងស្មើសិទ្ធិលើឆាកអន្តរជាតិ និងជារដ្ឋប្រជាធិបតេយ្យ ដែលមានអភិបាលកិច្ចល្អ និងស្ថាប័នរឹងមាំប្រកបដោយតម្លាភាព និងគណនេយ្យភាព ហើយដំណើការបម្រើជាតិ និងប្រជាជនប្រកបដោយប្រសិទ្ធភាព។

២. កម្ពុជា ជា "**ប្រទេសមានចំណូលខ្ពស់ និងមានសេដ្ឋកិច្ចធន់រឹងមាំ**" ប្រកបដោយប្រសិទ្ធភាព ភាពប្រកួតប្រជែងបើកចំហ បរិយាបន្ន និងចីរភាព ដោយរដ្ឋប្រកាន់យកតួនាទីជាយុទ្ធសាស្ត្រវិទូ អ្នកដឹកនាំ និងអ្នកគ្រប់គ្រងការអភិវឌ្ឍ ជាអ្នកការពារកម្មសិទ្ធិ និងទ្រព្យសម្បត្តិឯកជន និងជាអ្នកគាំទ្រ និងលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន។ នៅក្នុងការដឹកនាំ និងការគ្រប់គ្រងការអភិវឌ្ឍ រដ្ឋប្រកាន់យកនូវការបើកចំហឆ្ពោះទៅខាងក្រៅដោយពង្រឹង និងពង្រីកក្របខ័ណ្ឌពាណិជ្ជកម្មសេរី ទាំងទ្វេភាគី និងពហុភាគី ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការជំរុញធ្វើពិពិធកម្មសេដ្ឋកិច្ច ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល និងការបង្កើនភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ។

៣. ប្រជាជនកម្ពុជា "**មានចំណេះដឹងខ្ពស់ និងជំនាញមួយយ៉ាងតិចប្រចាំជីវិត**" ប្រកបដោយ អំណត់ធន់ សហគ្រិនភាព នវានុវត្តន៍ និងសីលធម៌ប្រពៃ ដោយរដ្ឋធានាផ្ដល់សេវាអប់រំជាមូលដ្ឋានសម្រាប់ទាំងអស់គ្នាយ៉ាងតិចត្រឹមថ្នាក់ទី៩ បំពាក់ជំនាញ និងបច្ចេកវិទ្យាដែលជាតម្រូវការទីផ្សារការងារ និងធុរកិច្ច ពង្រឹងការបណ្ដុះបណ្ដាល និងការផ្លាស់ប្ដូរជំនាញ ស្របនឹងតម្រូវការទីផ្សារការងារ ពង្រឹងគុណភាពវិស័យឧត្ដមសិក្សាឱ្យក្លាយជាមណ្ឌលមូលធនបញ្ញាជាតិ និងឃ្លាំងពុទ្ធិសកល និងយកចិត្តទុកដាក់លើជីវភាពគ្រូបង្រៀន បុគ្គលិក សិក្សា និងសាស្ត្រាចារ្យ។

៤. ប្រជាជនកម្ពុជា "**រស់នៅក្នុងសេចក្ដីថ្លៃថ្នូរ សុភមង្គល និងទទួលបានការគាំពារសង្គមប្រកបដោយសមធម៌ ស្មើសិទ្ធិ ស្មើឱកាស**" ក្នុងសង្គមជាតិដោយរដ្ឋផ្ដល់សារៈសំខាន់លើការរៀបចំឱ្យបានរឹងមាំនូវប្រព័ន្ធសន្តិសុខសង្គម និងជំនួយសង្គម ការលើកកម្ពស់វិស័យធានារ៉ាប់រង ការពង្រឹង និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល ការយកចិត្តទុកដាក់លើវិស័យកីឡា និងសុខភាពសាធារណៈ ការលើកកម្ពស់សមភាពយេនឌ័រ និងការលើកកម្ពស់សង្គមឌីជីថល។

៥. កម្ពុជា ជាប្រទេសមាន "**បរិស្ថានរូបវន្ត និងធម្មជាតិប្រកបដោយសុខដុមភាព ភាពធន់ បរិយាបន្ន និងតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិ**" សម្រាប់ការរស់នៅប្រកបដោយផាសុកភាព ដោយរដ្ឋផ្តល់សារៈសំខាន់ចំពោះសន្តិសុខថាមពល ការរៀបចំប្រព័ន្ធទឹកស្អាត និងប្រព័ន្ធគ្រប់គ្រងកាកសំណល់គ្រប់ប្រភេទប្រកបដោយប្រសិទ្ធភាព ការរៀបចំប្រព័ន្ធធារាសាស្ត្រតាមបែបទំនើប និងស្វ័យប្រវត្តិការទប់ទល់ និងការកសាងប្រព័ន្ធបន្សាំរឹងមាំទៅនឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព ការបំពាក់បច្ចេកវិទ្យាទាន់សម័យក្នុងវិស័យកសិកម្ម និងការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិដោយគិតគូរដល់តុល្យភាពបរិស្ថាន។

## ៣. គោលបំណង និងគោលដៅ

### ៣.១. គោលបំណង

គោលបំណងដ៏សំខាន់ដើម្បីសម្រេចបាននូវបេសកកម្ម និងចក្ខុវិស័យរបស់ក្រសួងមហាផ្ទៃ គឺ**ការលើកកម្ពស់ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់ថ្នាក់ ព្រមទាំងការពង្រឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដើម្បីឆ្លើយតបទៅនឹងតម្រូវការសំណើសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាប្រឈមនានាប្រកបដោយប្រសិទ្ធភាព គុណភាព គណនេយ្យភាព តម្លាភាព យុត្តិធម៌ បរិយាបន្ន និងសមធម៌សង្គម។**

### ៣.២. គោលដៅ

ដើម្បីសម្រេចគោលបំណងខាងលើ ក្រសួងមហាផ្ទៃនឹងសម្រួចការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនដោយផ្តោតលើគោលដៅជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៣ រួមមាន៖

១. ការអភិវឌ្ឍ និងការពង្រឹងស្ថាប័នក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាស្ថាប័នដែលមានរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ ធនធាន

និងការទទួលខុសត្រូវច្បាស់លាស់។

២. ការពង្រឹងប្រសិទ្ធភាពនៃការបំពេញការងារ និងការទទួលខុសត្រូវរបស់បុគ្គលិកក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការអភិវឌ្ឍសមត្ថភាពបុគ្គលិក ការពង្រឹងការគ្រប់គ្រងបុគ្គលិក ការពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ និងការលើកកម្ពស់ការអនុវត្តការងារតាមប្រព័ន្ធឌីជីថល។

៣. ការពង្រឹង និងការកែលម្អយន្តការ និងនីតិវិធីផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាល សេវាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឱ្យបានឆាប់រហ័ស មានលក្ខណៈទំនើប ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព យុត្តិធម៌ បរិយាបន្ន សមធម៌សង្គម និងការជឿទុកចិត្តពីប្រជាជន។

## ៤. គោលការណ៍ជាមូលដ្ឋាន

ក្នុងនាមជាស្ថាប័នដែលជាឆ្អឹងខ្នង និងជាសេនាធិការដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការផ្តល់សេវារដ្ឋបាល និងការគាំពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គមជូនប្រជាពលរដ្ឋ និងបំពេញតួនាទីជាស្ពានផ្សារភ្ជាប់គោលនយោបាយរបស់រាជរដ្ឋាភិបាលទៅជាការអនុវត្តជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសម្រេចបាននូវបេសកកម្ម និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃឆ្លើយតប និងដោះស្រាយបញ្ហាប្រឈម និងតម្រូវការនានារបស់ប្រជាជន មន្ត្រី បុគ្គលិកនៃក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគោរពនូវគោលការណ៍ជាមូលដ្ឋានដូចខាងក្រោម៖

- ត្រូវតម្កល់ផលប្រយោជន៍ជាតិ និងប្រជាជនជាធំ
- ត្រូវមានឆន្ទៈមុតស្រួច ម៉ឺងម៉ាត់ និងហ៊ានពលិកម្មក្នុងការការពារសុខសន្តិភាព ឯករាជ្យជាតិ បូរណភាពទឹកដី អធិបតេយ្យភាពជាតិ ស្ថាប័នព្រះមហាក្សត្រ និងស្ថាប័នជាតិនានា
- ត្រូវចាត់ទុកថា តម្រូវការសេវា និងបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ គឺជាកាតព្វកិច្ចរបស់មន្ត្រីសាធារណៈដែលត្រូវឆ្លើយតប និងដោះស្រាយឱ្យបានទាន់ពេលវេលា

- ត្រូវគោរពច្បាប់ ប្រកាន់ខ្ជាប់ក្រមសីលធម៌វិជ្ជាជីវៈ មានសាមគ្គីភាពផ្ទៃក្នុងរឹងមាំ មានភាពស្មោះត្រង់និងការទទួលខុសត្រូវខ្ពស់ ធានាឱ្យមានយុត្តិធម៌បរិយាបន្ន និងសមធម៌សង្គម
- ត្រូវមានការអភិវឌ្ឍសមត្ថភាពជំនាញ និងបច្ចេកវិទ្យាឌីជីថលជាប្រចាំ មានគំនិតផ្តួចផ្តើមថ្មីៗ និងនវានុវត្តន៍ប្រកបដោយភាពច្នៃប្រឌិតជឿនលឿន។

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រង និងការបំពេញការងាររបស់មន្ត្រីបុគ្គលិកប្រកបដោយការទទួលខុសត្រូវ និងភាពស្អាតស្អំស្របតាមគោលការណ៍ជាមូលដ្ឋានខាងលើ ក្រសួងមហាផ្ទៃប្រកាន់ខ្ជាប់នូវអភិក្រមទាំង៥របស់រាជរដ្ឋាភិបាលគឺ **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"**។

## ៥. យុទ្ធសាស្ត្រ

ដើម្បីឈានទៅសម្រេចគោលបំណង និងគោលដៅដូចបានកំណត់ខាងលើ ក្រសួងមហាផ្ទៃផ្តោតលើយុទ្ធសាស្ត្រសំខាន់ៗ**ចំនួន៦** ដូចខាងក្រោម៖

### យុទ្ធសាស្ត្រទី១៖ ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ

យុទ្ធសាស្ត្រទី១នេះ ផ្តោតទៅលើការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ (រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធាន) ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ការពង្រឹងប្រសិទ្ធភាពនៃការបំពេញការងារ ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈតាមប្រព័ន្ធឌីជីថល និងពង្រឹងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

យុទ្ធសាស្ត្រនេះរួមមាន ៥សកម្មភាពជាអាទិភាព ដូចខាងក្រោម៖

**សកម្មភាពទី១៖ ការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង មុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ឱ្យស្របទៅតាមចរិតលក្ខណៈ

(ជាទីក្រុង ទីប្រជុំជន និងតំបន់ជនបទ) ប្រភេទ(ជារដ្ឋបាលទីក្រុងធំ រដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋាន) និងសក្តានុពលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗឱ្យក្លាយជារដ្ឋបាលដែលសមត្ថភាពខ្ពស់ វៃឆ្លាត និងស្អាតស្អំ។

សកម្មភាពទី២៖ **ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ** តាមរយៈការពង្រឹង និងកែលម្អយន្តការ នីតិវិធី និងស្តង់ដានៃការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព គុណភាព តម្លាភាព ឆាប់រហ័ស ងាយស្រួល បរិយាបន្ន និងសមធម៌សង្គម ព្រមទាំងពង្រឹងយន្តការផ្តល់ព័ត៌មាន ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការដោយឆាប់រហ័ស តម្លាភាព យុត្តិធម៌ និងភាពជឿទុកចិត្ត។

សកម្មភាពទី៣៖ **ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា និងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ**ក្នុងការដឹកនាំ គ្រប់គ្រង ចាត់ចែងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព គុណភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

សកម្មភាពទី៤៖ **ការពង្រឹង និងការពង្រីកកិច្ចសហប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌតំបន់ និងសាកល និងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន** ដើម្បីកៀរគរការចូលរួមដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

សកម្មភាពទី៥៖ **ការពង្រឹងការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការបំពេញការងារ ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើសវនកម្មនិងអធិការកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ដើម្បីធានាភាពត្រឹមត្រូវតាមច្បាប់ បែបបទ នីតិវិធី និងស្តង់ដាដែលបានកំណត់។

## យុទ្ធសាស្ត្រទី២៖ ការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម

យុទ្ធសាស្ត្រទី២នេះ ផ្តោតទៅលើការបន្តការពារឱ្យបានដាច់ខាតនូវសន្តិភាព ឯករាជ្យ អធិបតេយ្យភាពជាតិ បូរណភាពទឹកដី ស្ថិរភាពនយោបាយ និងការធានារក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមដែលជាបុរេលក្ខខណ្ឌមិនអាចខ្វះបានសម្រាប់ការលើកកម្ពស់សិទ្ធិសេរីភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រទេសជាតិ។

យុទ្ធសាស្ត្រនេះរួមមាន ៥សកម្មភាពជាអាទិភាព ដូចខាងក្រោម៖

**សកម្មភាពទី១៖ ការការពារសន្តិភាព ឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី និងខឿនសន្តិសុខជាតិ** តាមរយៈ (១)ការរួមចំណែកការពារដាច់ខាតនូវសន្តិភាព អធិបតេយ្យជាតិ បូរណភាពទឹកដីធានាមិនឱ្យមានការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងកម្ពុជា (២)ការទប់ស្កាត់រាល់ឧបាយកលសកម្មភាពប៉ុនប៉ងប្រើប្រាស់ទឹកដីកម្ពុជាប្រឆាំងប្រទេសជិតខាង (៣)ការចាត់វិធានការបង្ការ ការទប់ស្កាត់ និងការប្រឆាំងដាច់ខាតនូវអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសបច្ចេកវិទ្យា និងឧបាយកលសកម្មភាពវិច្ឆេទកម្ម វិទ្ធង្សនាបង្កចលាចលផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ឬការញុះញង់ណាមួយដែលបង្កឱ្យមានអស្ថិរភាពនយោបាយក្នុងសង្គម (៤)ការការពាររបបរាជានិយម ការការពាររបបប្រជាធិបតេយ្យសេរីពហុបក្ស ការធានាប្រក្រតីកម្មស្ថាប័នជាតិ ការពារគោលដៅនយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ ការធានាសុវត្ថិភាពជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងព្រឹត្តិការណ៍ជាតិ-អន្តរជាតិដែលប្រារព្ធធ្វើឡើងនៅកម្ពុជា (៥)ការប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និង(៦)ការពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីទាំងក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាប

បទល្មើសគ្រប់ប្រភេទ និងរួមចំណែកកសាងព្រំដែនសន្តិភាព មិត្តភាព និងការអភិវឌ្ឍនៅតាមព្រំដែនជាមួយប្រទេសជិតខាង។

**សកម្មភាពទី២៖ ការរក្សាសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម** តាមរយៈការពង្រឹង និងការលើកកម្ពស់ការគ្រប់គ្រង ការដឹកនាំ ការបញ្ជា និងការចាត់វិធានការលើការងារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជាពិសេសលើការអនុវត្តគោលនយោបាយ "**ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព**" ដោយផ្ដោតជាសំខាន់ទៅលើ (១)ការចាត់វិធានការកាត់បន្ថយបទល្មើសលួច ឆក់ ប្លន់ ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសផ្សេងៗទៀត (២)ការជំរុញការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ តាមរយៈការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀន ការអប់រំផ្សព្វផ្សាយ ការព្យាបាលនិងស្ដារនីតិសម្បទា ការបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងបំណិនជីវិត ការចាកចេញពីគ្រឿងញៀននិងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា (៣)ការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទ ក្មេងទំនើង និងអំពើហិង្សាក្នុងគ្រួសារ និង(៤)ការចាត់វិធានការកាត់បន្ថយគ្រោះថ្នាក់សង្គម ពិសេសគ្រោះថ្នាក់ចរាចរណ៍ អគ្គីភ័យ ការប្រើប្រាស់អាវុធខុសច្បាប់ និងសំណល់គ្រឿងផ្ទុះសល់ពីសង្គ្រាម និងការចាត់វិធានការដោះស្រាយការកកស្ទះចរាចរណ៍ ព្រមទាំងការរៀបចំសណ្ដាប់ធ្នាប់សាធារណៈ។

**សកម្មភាពទី៣៖ ការពង្រឹង និងការអភិវឌ្ឍការងារនគរបាល និងសហគមន៍** តាមរយៈ (១)ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងលើកកម្ពស់សមត្ថភាពមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល (២)ការពង្រឹង និងការជំរុញសកម្មភាពនៃយន្តការគ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យការងារប៉ុស្តិ៍នគរបាល

រដ្ឋបាល (៣)ការសិក្សាស្រាវជ្រាវ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងគាំទ្រប៉ុស្តិ៍នគរបាលរដ្ឋបាល (៤)ការពង្រឹង និងការពង្រីកកម្លាំងបង្អែកនៅមូលដ្ឋាន ដើម្បីគាំទ្រដល់ចលនាការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និង(៥)ការជំរុញការកសាងប្រព័ន្ធទទួល និងផ្តល់ព័ត៌មាន(E-Police)សម្រាប់បង្កើនទំនាក់ទំនងរវាងនគរបាលប៉ុស្តិ៍រដ្ឋបាល និងសហគមន៍។

សកម្មភាពទី៤៖ **ការពង្រឹងការគ្រប់គ្រងច្រកទ្វារព្រំដែន ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ បង្កើនការផ្តល់សេវាអន្តោប្រវេសន៍ និងពង្រឹង ពង្រីកចំណងមិត្តភាព សហប្រតិបត្តិការជាតិ និងអន្តរជាតិ** តាមរយៈ(១)ការពង្រឹងការគ្រប់គ្រងច្រកទ្វារគ្រប់ប្រភេទ និងការលើកកម្ពស់សេវាផ្តល់ទិដ្ឋាការអន្តោប្រវេសន៍ (២)ការពង្រឹងការគ្រប់គ្រងវត្តមានស្នាក់នៅរបស់ជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា (៣)ការបង្កើនការធ្វើអធិការកិច្ចហត្ថពលកម្មបរទេស (៤)ការពង្រឹងវិធានការបង្ការទប់ស្កាត់ការជ្រៀតចូលខុសច្បាប់ ស្រាវជ្រាវ ស៊ើបអង្កេត ស្វែងរកជនបរទេសដែលលួចស្នាក់នៅខុសច្បាប់ដើម្បីចាត់វិធានការតាមច្បាប់ (៥)ការពង្រឹង និងការពង្រីកចំណងមិត្តភាព សហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ និង(៦)ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាអន្តោប្រវេសន៍សម្រាប់ការគ្រប់គ្រងអន្តោប្រវេសន៍តាមបែបឌីជីថល។

សកម្មភាពទី៥៖ **ការពង្រឹងការងារអត្តសញ្ញាណកម្មដើម្បីធានាសម្រេចបានគោលដៅ "បុគ្គលម្នាក់មានអត្តសញ្ញាណតែមួយ" និង "មនុស្សទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណ"** ដោយផ្តោតលើ (១)ការរៀបចំលិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការអនុវត្តច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (២)ការកែលម្អប្រព័ន្ធ និងនីតិវិធីចុះបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ បញ្ជីអត្តសញ្ញាណកម្មផ្សេងទៀត (៣)ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យប្រជាជន

(៤)ការអភិវឌ្ឍសមត្ថភាពមន្ត្រីអត្រានុកូលដ្ឋាន (៥) ការផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីសារសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះបញ្ជីអត្តសញ្ញាណកម្មផ្សេងទៀត។

## យុទ្ធសាស្ត្រទី៣៖ ការលើកកម្ពស់ការគ្រប់គ្រងពន្ធនាគារ

យុទ្ធសាស្ត្រទី៣នេះ ផ្តោតទៅលើការគ្រប់គ្រងពន្ធនាគារតាមបទដ្ឋាន ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ការទប់ស្កាត់ការប្រព្រឹត្តបទល្មើសសារជាថ្មី និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ។

យុទ្ធសាស្ត្រនេះរួមមាន ៣សកម្មភាពជាអាទិភាព ដូចខាងក្រោម៖

**សកម្មភាពទី១៖ ការពង្រឹងការគ្រប់គ្រងពន្ធនាគារតាមស្តង់ដាដែលធានាឱ្យមានសន្តិសុខ សុវត្ថិភាព សុខភាព និងមនុស្សធម៌** តាមរយៈ(១)ការពង្រឹងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ពន្ធនាគារ (២)ការពិនិត្យការកែសម្រួល និងការពង្រឹងការអនុវត្តនីតិវិធី និងស្តង់ដានៃការគ្រប់គ្រងពន្ធនាគារ (៣)ការលើកកម្ពស់ការផ្តល់សេវាជំនួយផ្នែកច្បាប់ និងសេវាព័ត៌មានសម្រាប់ជនជាប់ឃុំ និង(៤)ការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាព ជីវភាពជនជាប់ឃុំ និងអនាម័យ បរិស្ថានក្នុងពន្ធនាគារ។

**សកម្មភាពទី២៖ ការអភិវឌ្ឍជំនាញវិជ្ជាជីវៈផ្តល់សេវាអប់រំកែប្រែ ការស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនជាប់ឃុំ និងការធ្វើសមាហរណកម្មជនដែលត្រូវបានដោះលែងទៅក្នុងសហគមន៍** តាមរយៈ(១)ការផ្តល់ការអប់រំកែប្រែ និងផ្តល់នីតិសម្បទាដល់ជនជាប់ឃុំដូចជាការអប់រំចំណេះដឹងទូទៅ ភាសាបរទេស កុំព្យូទ័រ បំណិនជីវិត និងការអប់រំផ្លូវចិត្តជាដើម និង(២)ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងមុខរបរដល់ជនជាប់ឃុំ ដើម្បីមានមុខរបរចិញ្ចឹមជីវិតក្រោយធ្វើសមាហរណកម្មទៅក្នុងសហគមន៍។

**សកម្មភាពទី៣៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពន្ធនាគារ និងការបំពាក់នូវឧបករណ៍សម្ភារ**ឱ្យស្របតាមស្តង់ដាពន្ធនាគារដែលធានាបាននូវសន្តិសុខ សុវត្ថិភាព និងសុខភាពស្របតាមគោលការណ៍មនុស្សធម៌។

## យុទ្ធសាស្ត្រទី៤៖ ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស

យុទ្ធសាស្ត្រទី៤នេះ ផ្តោតទៅលើការពង្រឹង ការកែទម្រង់ស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្សក្នុងក្របខ័ណ្ឌនៃក្រសួងមហាផ្ទៃ តាមរយៈការធ្វើវិចារណកម្មមុខងារ តួនាទី ភារកិច្ចឱ្យបានច្បាស់លាស់តាមអង្គភាពនីមួយៗនៃក្រសួងមហាផ្ទៃ ការអភិវឌ្ឍស្ថាប័នបណ្តុះបណ្តាល ការពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងអភិបាលកិច្ចក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម ព្រមទាំងលើកកម្ពស់ភាពស្អាតស្អំក្នុងការបំពេញការងារ។

យុទ្ធសាស្ត្រនេះរួមមាន ៧សកម្មភាពជាអាទិភាព ដូចខាងក្រោម៖

**សកម្មភាពទី១៖ ការធ្វើវិចារណកម្មមុខងារ រចនាសម្ព័ន្ធស្ថាប័ន របៀបរបបធ្វើការងារ និងទំនើបកម្មស្ថាប័ន**ឱ្យឆ្លើយតបទៅនឹងទំហំការងារ និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ស្របតាមកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ការវិវឌ្ឍនៃកំណែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាល និងបេសកកម្មរបស់ក្រសួងមហាផ្ទៃ ដើម្បីប្រែក្លាយឱ្យទៅជាស្ថាប័នមានសមត្ថភាពខ្ពស់ វៃឆ្លាត ស្អាតស្អំ និងនវានុវត្តន៍។

**សកម្មភាពទី២៖ ការពង្រឹងការគ្រប់គ្រងធនធានមនុស្ស**ស្របតាមច្បាប់ លក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីរាជការស៊ីវិល នគរបាលជាតិ និងមន្ត្រីពន្ធនាគារ និងស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងមន្ត្រីរាជការតាមរយៈ(១)ការរៀបចំផែនការបុគ្គលិកដោយផ្អែកលើការវាយតម្លៃតម្រូវការធនធានមនុស្ស (២)ការជ្រើសរើសប្រកបដោយតម្លាភាព

យុត្តិធម៌ គុណាធិបតេយ្យ បរិយាបន្ន និងសមធម៌សង្គម (៣)ការរៀបចំការពិពណ៌នាមុខតំណែង និងលក្ខខណ្ឌការងាររបស់បុគ្គលិកឱ្យបានច្បាស់លាស់ (៤)ការរៀបចំក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យការងារ (៥)ការពង្រឹងការតែងតាំង ការតម្លើងថ្នាក់ ឋានន្តរស័ក្តិ ការដាក់វិន័យ និងការប្រែប្រួលស្ថានភាពរដ្ឋបាលផ្សេងទៀតរបស់បុគ្គលិកស្របតាមច្បាប់ គោលការណ៍ និងនីតិវិធីកំណត់ (៦)ការវាយតម្លៃបុគ្គលិកដោយផ្អែកលើសមិទ្ធកម្ម (៧)ការរៀបចំប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិក និង(៨)ការពង្រឹងការដឹកនាំ ការគ្រប់គ្រង និងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗ។

**សកម្មភាពទី៣៖ ការអភិវឌ្ឍធនធានមនុស្ស** តាមរយៈ(១)ការវាយតម្លៃតម្រូវការអភិវឌ្ឍធនធានមនុស្ស (២)ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិកសម្រាប់រយៈពេលខ្លី មធ្យម និងវែង (៣)ការអភិវឌ្ឍស្ថាប័នបណ្តុះបណ្តាលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ដូចជាបណ្ឌិត្យសភានគរបាលកម្ពុជា សាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈមន្ត្រីនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ និង(៤)ការអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំ និងបុគ្គលិកឱ្យមានសមត្ថភាព មានជំនាញវិជ្ជាជីវៈច្បាស់លាស់ ដោយត្រូវផ្តោតការយកចិត្តទុកដាក់លើថ្នាក់ដឹកនាំ និងបុគ្គលិកជាស្ត្រី តាមរយៈកិច្ចសហការប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ។

**សកម្មភាពទី៤៖ ការពង្រឹងប្រសិទ្ធភាពនៃការរៀបចំ និងការគ្រប់គ្រងផែនការ ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ** តាមរយៈ (១)ការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រនានាក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ (២)ការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពប្រចាំឆ្នាំរបស់ក្រសួង

មហាផ្ទៃ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៣)ការពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងការទទួលខុសត្រូវ តាមរយៈការរៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃឱ្យបានទៀងទាត់ និងច្បាស់លាស់ ស្របតាមច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ (៤)ការពង្រឹងការបែងចែក និងការផ្គត់ផ្គង់ភស្តុភារ និងសម្ភារបច្ចេកទេសឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព និង(៥)ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសំណង់ និងវិស្វកម្ម និងការស្រាវជ្រាវ បទដ្ឋានឧបករណ៍បច្ចេកទេស។

**សកម្មភាពទី៥៖ ការពង្រឹងការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ** តាមរយៈ (១)ការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សានីតិកម្ម និងអង្គភាពរៀបចំគោលនយោបាយ (២)ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាដែលបម្រើឱ្យតម្រូវការនៃការអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ (៣)ការផ្សព្វផ្សាយ ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងការផ្តល់គោលការណ៍ណែនាំតម្រង់ទិសដល់ការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាបាននូវការរៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋានទាំងនោះស្របតាមទម្រង់ នីតិវិធីដែលមានកំណត់ និងមានសង្គតិភាព។

**សកម្មភាពទី៦៖ ការលើកកម្ពស់ការសិក្សាស្រាវជ្រាវលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ពន្ធនាគារ ការអភិវឌ្ឍមូលដ្ឋាន អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ព្រមទាំងការជំរុញនវានុវត្តន៍ និង**

**ការងារពាក់ព័ន្ធផ្សេងទៀត** តាមរយៈ (១)ការបង្កើនសកម្មភាពស្រាវជ្រាវ និងការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ (២)ការរៀបចំមណ្ឌលចំណេះដឹងអំពីការអភិវឌ្ឍមូលដ្ឋាន និង(៣)ការលើកកម្ពស់សមត្ថភាពនវានុវត្តន៍។

**សកម្មភាពទី៧៖ ការពង្រឹងការអនុវត្តការងារសវនកម្មផ្ទៃក្នុងការធ្វើអធិការកិច្ច និងដោះស្រាយបណ្តឹងក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃឱ្យបានត្រឹមត្រូវ តម្លាភាព និងប្រសិទ្ធភាព** តាមរយៈ(១)ការរៀបចំ និងការអនុវត្តផែនការសវនកម្មផ្ទៃក្នុងឱ្យបានទៀងទាត់ និងតាមភាពចាំបាច់នៅតាមបណ្តាអង្គភាពនានាក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ លើកអនុសាសន៍ និងតាមដានការអនុវត្តតាមអនុសាសន៍របស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (២)ការពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកជំនាញសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ និង(៣) ការធ្វើអធិការកិច្ច និងការដោះស្រាយបណ្តឹងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

## យុទ្ធសាស្ត្រទី៥៖ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ

យុទ្ធសាស្ត្រទី៥នេះ ផ្តោតទៅលើការពង្រឹង និងការកែលម្អយន្តការ នីតិវិធី និងស្តង់ដានៃការផ្តល់សេវាសាធារណៈក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃឱ្យមានភាពសាមញ្ញ ក្រមសីលធម៌វិជ្ជាជីវៈ គណនេយ្យភាព ភាពជឿទុកចិត្ត និងតម្លាភាព។

យុទ្ធសាស្ត្រនេះរួមមាន ៤សកម្មភាពជាអាទិភាព ដូចខាងក្រោម៖

**សកម្មភាពទី១៖ ការពង្រឹង ការកែលម្អយន្តការ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃតាមយន្តការច្រកចេញចូលតែមួយ** រួមមានដូចជា (១)ការផ្តល់សេវាចុះបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ និង

បញ្ជីអត្តសញ្ញាណកម្ម (២)ការផ្តល់សេវាទិដ្ឋាការអន្តោប្រវេសន៍ ដូចជាការផ្តល់សេវាផ្តល់ទិដ្ឋាការចូលប្រទេស ការបន្តសុពលភាពទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន និងការផ្តល់ទិដ្ឋាការចេញជូនជនបរទេសឱ្យកាន់តែឆាប់រហ័ស និងកាន់តែងាយស្រួល (៣)ការផ្តល់សេវាលើការចុះបញ្ជីគណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិច និងសេវារដ្ឋបាលផ្សេងៗទៀតក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ ដើម្បីធានាដល់ការផ្តល់សេវាទាំងនេះឱ្យកាន់តែសាមញ្ញ ងាយស្រួល ឆាប់រហ័ស តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្ត។

**សកម្មភាពទី២៖ ការពង្រឹងប្រសិទ្ធភាពសេវាសុខាភិបាលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ** តាមរយៈ (១)ការពង្រឹងសមត្ថភាពគ្រូពេទ្យជំនាញ ការបំពាក់បំប៉នបន្ថែមក្រៅប្រទេស និងតាមបណ្តាមន្ទីរពេទ្យធំៗក្នុងស្រុក (២)ការពង្រឹងកម្មវិធីអប់រំសុខភាព និងបង្ការជំងឺឆ្លងជូនកងកម្លាំងនគរបាលជាតិ និងមន្ត្រី បុគ្គលិកក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ (៣)ការបង្កើតគិលានដ្ឋានតាមស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដើម្បីផ្តល់សេវាសុខាភិបាលកាន់តែរហ័ស ទាន់ពេលវេលា ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

**សកម្មភាពទី៣៖ ការពង្រឹង និងការកែលម្អយន្តការនិងនីតិវិធីទទួលដោះស្រាយបណ្តឹងតវ៉ា និងការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ** ផ្តោតលើ (១)លើកកម្ពស់ការចូលរួម និងការជឿទុកចិត្តមកលើការបំពេញការងារ និងការផ្តល់សេវាសាធារណៈរបស់អង្គភាពផ្តល់សេវា តាមរយៈយន្តការផ្តល់ព័ត៌មាននានាតាមបែបទំនើប និងតាមបែបប្រពៃណី (២)ពង្រឹងយន្តការទទួលបណ្តឹងតវ៉ានានាតាមរយៈការទទួលផ្ទាល់ តាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (Hotline) និងតាមប្រព័ន្ធទំនាក់ទំនងសង្គម

និង (៣)ពង្រឹងយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចក្រសួងមហាផ្ទៃ។

**សកម្មភាពទី៤៖ ការលើកកម្ពស់ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ សមាគម អង្គការមិនមែនរដ្ឋាភិបាល** ដើម្បីចូលរួមក្នុងការរៀបចំគោលនយោបាយនានា និងការកៀរគរធនធាននានាគាំទ្រដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍក្នុងដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

## យុទ្ធសាស្ត្រទី៦៖ ការងារបច្ចេកវិទ្យាឌីជីថល

យុទ្ធសាស្ត្រទី៦នេះ ផ្តោតទៅលើការធ្វើបរិវត្តកម្មឌីជីថល ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដែលរួមមាន៣សកម្មភាពជាអាទិភាពដូចខាងក្រោម៖

**សកម្មភាពទី១៖ ការពង្រឹងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល** តាមរយៈ(១)ការរៀបចំដំឡើងឧបករណ៍បច្ចេកទេស និងប្រព័ន្ធបច្ចេកវិទ្យាគាំទ្រក្នុងមជ្ឈមណ្ឌលទិន្នន័យនៃទីស្តីការក្រសួងមហាផ្ទៃ (២)ការរៀបចំដំឡើងឧបករណ៍បច្ចេកទេស និងប្រព័ន្ធបច្ចេកវិទ្យាគាំទ្រសម្រាប់ថ្នាលទិន្នន័យក្រសួងមហាផ្ទៃ (Data Exchange Gateway) (៣)ការរៀបចំទំនើបកម្មមជ្ឈមណ្ឌលទិន្នន័យនៃទីស្តីការក្រសួងមហាផ្ទៃពីកម្រិតមធ្យមទៅកម្រិតខ្ពស់ (៤) ការរៀបចំតភ្ជាប់បណ្តាញហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរវាងអង្គភាពចំណុះក្រសួងមហាផ្ទៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (៥)ការរៀបចំ និងអនុវត្តយន្តការការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល រួមមានគោលនយោបាយ និងបទដ្ឋានគតិយុត្ត (៦)ការដំឡើងមជ្ឈមណ្ឌលការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល (SOC) តាមដានការវាយប្រហារ និងជ្រៀតចូលប្រព័ន្ធបច្ចេកវិទ្យាក្របខ័ណ្ឌក្រសួងមហាផ្ទៃ (៧)ការរៀបចំ និងអនុវត្តយន្តការការពារ

សន្តិសុខសណ្តាប់ធ្នាប់សាធារណៈបច្ចេកវិទ្យាឌីជីថល ដើម្បីគាំទ្រដល់កិច្ចការពារសុវត្ថិភាព និងការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា និង(៨)ការបំពាក់ប្រព័ន្ធកាមេរ៉ាវៃឆ្លាតបម្រើការងារចរាចរណ៍ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈទូទាំងរាជធានី ខេត្ត។

**សកម្មភាពទី២៖ ការលើកកម្ពស់ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យាឌីជីថលបម្រើដល់ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការគ្រប់គ្រងរដ្ឋបាលទូទៅ** តាមរយៈ(១)ការរៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្សព្វផ្សាយ ប្រព័ន្ធតាមដាន ប្រមូល វិភាគព័ត៌មាន និងឆ្លើយតបក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ (២)ការរៀបចំ និងធ្វើឱ្យប្រសើរឡើងប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍សម្រាប់ប្រជាពលរដ្ឋ (៣)ការរៀបចំ និងអភិវឌ្ឍប្រព័ន្ធកម្មវិធីជំនួយបន្ទាន់របស់ក្រសួងមហាផ្ទៃសម្រាប់ប្រជាជនកម្ពុជា (៤)ការរៀបចំ និងដាក់ឱ្យប្រើប្រាស់ថ្នាលឌីជីថលសម្រាប់ការគ្រប់គ្រង និងការផ្តល់សេវារដ្ឋបាលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ (៥)ការរៀបចំ និងការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការងារតាមប្រព័ន្ធឌីជីថល ដូចជា ប្រព័ន្ធគ្រប់គ្រងបុគ្គលិក ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ល។ និង(៦)ការរៀបចំ និងការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមអង្គភាពជំនាញ ដូចជាប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជនដែលជាប្រព័ន្ធស្នូលទិន្នន័យ អត្តសញ្ញាណបុគ្គល និងជាប្រព័ន្ធសម្រាប់គ្រប់គ្រងលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ ប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិ និងការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប្រព័ន្ធលិខិតឆ្លងដែន ប្រព័ន្ធឯកភាពបែងចែកទិន្នន័យប្រជាជន ប្រព័ន្ធទិន្នន័យគ្រប់គ្រងអន្តោប្រវេសន៍ ការរៀបចំប្រព័ន្ធបណ្តុះបណ្តាលតាមបច្ចេកវិទ្យាឌីជីថល ប្រព័ន្ធទិន្នន័យគ្រប់គ្រងជនជាប់ឃុំ ជាដើម។

**សកម្មភាពទី៣៖ ការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ការផ្សព្វផ្សាយអប់រំ ការបញ្ជ្រាបចំណេះដឹង និងការពង្រឹងជំនាញឌីជីថល** តាមរយៈ (១)ការរៀបចំវគ្គបណ្ដុះបណ្ដាលចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យាឌីជីថល (២)ការរៀបចំវគ្គបណ្ដុះបណ្ដាលចំណេះដឹងបច្ចេកវិទ្យាឌីជីថល សម្រាប់មន្ត្រីជំនាញ (៣)ការរៀបចំវគ្គបណ្ដុះបណ្ដាលជំនាញឌីជីថលតាមប្រព័ន្ធអនឡាញ និងរៀបចំឯកសារជំនួយស្មារតីជាទម្រង់ឌីជីថល (៤)ការរៀបចំយន្តការវាយតម្លៃ និងការកែសម្រួលវគ្គបណ្ដុះបណ្ដាលបច្ចេកវិទ្យាឌីជីថល និង(៥)ការពង្រឹង និងការធ្វើទំនើបកម្មការងារផ្សព្វផ្សាយអប់រំ និងការបញ្ជ្រាបចំណេះដឹងអំពីហានិភ័យ និងការបង្ការទប់ស្កាត់បទល្មើសបច្ចេកវិទ្យាព័ត៌មាន។

## ៦. ការគ្រប់គ្រងការអនុវត្ត

ផែនការយុទ្ធសាស្ត្រស្ដីពីការលើកកម្ពស់ការគ្រប់គ្រងដែនដី សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ គឺជាផែនទីបង្ហាញផ្លូវរយៈពេលមធ្យមពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ សម្រាប់ធានាដល់ការបំពេញបេសកកម្ម តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃឆ្លើយតបទៅនឹងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

ការអនុវត្តផែនការយុទ្ធសាស្ត្រនេះស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយមានអគ្គលេខាធិការដ្ឋានជាអង្គភាពសម្របសម្រួល គាំទ្រ តាមដានត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបលើការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ផែនការយុទ្ធសាស្ត្រនេះត្រូវអនុវត្តដោយអង្គភាពនានាចំណុះក្រសួង។

ក្នុងន័យខាងលើនេះ អង្គភាពចំណុះទាំងអស់នៃក្រសួងមហាផ្ទៃត្រូវពិនិត្យធ្វើបច្ចុប្បន្នភាព និងរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួនឱ្យស្របជាមួយផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ដើម្បីធានាដល់ការសម្រេចបាននូវសូចនាករ គោលដៅ និងគោលបំណងដែលបានកំណត់។ ផែនការយុទ្ធសាស្ត្ររបស់អង្គភាពនីមួយៗ គឺជាមូលដ្ឋានសំខាន់សម្រាប់ការរៀបចំ

ផែនការយុទ្ធសាស្ត្រថវិកា ផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុទទួលខុសត្រូវក្នុងការបូកសរុប និងរៀបចំផែនការយុទ្ធសាស្ត្រថវិកា គម្រោងថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងជំនួយហិរញ្ញប្បទាន ផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពនីមួយៗ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក៏ទទួលខុសត្រូវក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ ការតាមដាន និងការគាំទ្រអង្គភាពចំណុះនានាក្នុងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ព្រមទាំងបូកសរុប និងរៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍន៍ប្រចាំឆ្នាំ រួមជាមួយបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អគ្គលេខាធិការដ្ឋាន និងអង្គភាពនានារបស់ក្រសួងមហាផ្ទៃត្រូវលើកកម្ពស់ការសម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា ដើម្បីកៀរគរចូលរួម និងគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងមហាផ្ទៃ និងផែនការយុទ្ធសាស្ត្ររបស់អង្គភាពនីមួយៗ។

## ៧. គម្រោងថវិកា

ការប៉ាន់ស្មានចំណាយសរុបនៃផែនការយុទ្ធសាស្ត្រក្រសួងមហាផ្ទៃ ត្រូវបានគណនាទៅតាម សកម្មភាពជាអាទិភាពនានាដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនីមួយៗ។ ជារួម ចំណាយទាំងនេះរួមមានចំណាយសម្រាប់បុគ្គលិក ប្រតិបត្តិការរដ្ឋបាល ការផ្តល់សេវា និងការវិនិយោគ។

ថវិកាសម្រាប់គាំទ្រចំណាយទាំងនេះ គឺជាការទទួលខុសរួមរបស់ក្រសួងមហាផ្ទៃ និងការទទួលខុសត្រូវដោយឡែករបស់អង្គភាពនីមួយៗស្របទៅតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ ក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រនេះ ក្រសួងមហាផ្ទៃនឹងខិតខំកៀរគរការចូលរួមជាធនធានថវិកា និងមិនមែនថវិកា ព្រមទាំងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

ថវិការដ្ឋប៉ាន់ស្មានសរុបនៃផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ មានចំនួន **១២.៦៤១.៦៨៦លានរៀល** សមមូលនឹង **៣.១៦០លានដុល្លារអាមេរិក**។ ថវិកាប៉ាន់ស្មានក្នុងមួយឆ្នាំៗគិតជាមធ្យមប្រមាណចំនួន **២.៥២៨.៣៣៧លានរៀល** សមមូលនឹង **៦៣២លានដុល្លារអាមេរិក**។

## ៨. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ គឺជាការកិច្ចការដ៏មានសារៈសំខាន់ដើម្បីធានាថា សកម្មភាពជាអាទិភាពនានាត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពស្របតាមពេលវេលា និងធនធានដែលបានកំណត់ សំដៅសម្រេចបាននូវយុទ្ធសាស្ត្រ និងគោលដៅស្របតាមផែនការគ្រោងទុក។ ក្នុងន័យនេះ សូចនាករ និងចំណុចដៅតាមយុទ្ធសាស្ត្រនីមួយៗដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រនេះ គឺជាឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

អគ្គលេខាធិការដ្ឋាននៃក្រសួងមហាផ្ទៃ ជាអង្គភាពទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងមហាផ្ទៃ ដែលត្រូវធ្វើឡើងជាប្រចាំឆ្នាំ និងចុងបញ្ចប់នៃផែនការយុទ្ធសាស្ត្រ។

អង្គភាពប្រតិបត្តិនីមួយៗចំណុះក្រសួងមហាផ្ទៃត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ខ្លួន និងត្រូវផ្តល់ការសហការ និងចូលរួមក្នុងដំណើរការនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃ។

សកម្មភាព និងវិធីសាស្ត្រសំខាន់ៗសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រក្រសួងមហាផ្ទៃ រួមមានដូចខាងក្រោម ៖

### ៨.១. ការរៀបចំទិន្នន័យដើមគ្រា

ដើម្បីជាមូលដ្ឋានសម្រាប់ការវាស់វែងវឌ្ឍនភាពនៃលទ្ធផលនានា ដែលបានកំណត់ក្នុងតារាងសូចនាករ និងចំណុចដៅតាមយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រ

ក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋានត្រូវរៀបចំចងក្រងទិន្នន័យដើមគ្រាដោយផ្អែកទៅលើតារាងសូចនាករ និងចំណុចដៅនៃផែនការយុទ្ធសាស្ត្រ តាមរយៈការប្រើប្រាស់ទិន្នន័យ និងព័ត៌មាននានាដែលមានស្រាប់ ដូចជាទិន្នន័យពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងបទល្មើស សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍសមត្ថភាព ការគ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ការធ្វើសវនកម្មផ្ទៃក្នុង របាយការណ៍ស្តីពីការវាយតម្លៃ និងឯកសារពាក់ព័ន្ធផ្សេងទៀត។

ការរៀបចំចងក្រងទិន្នន័យដើមគ្រា ត្រូវធ្វើឡើងក្នុងឆ្នាំទី១នៃផែនការយុទ្ធសាស្ត្រនេះ។

### ៤.២. ការតាមដានត្រួតពិនិត្យ

ការតាមដានត្រួតពិនិត្យ ជាដំណើរការដែលត្រូវអនុវត្តជាប្រចាំ។ អគ្គលេខាធិការដ្ឋានត្រូវរៀបចំកិច្ចប្រជុំជាមួយអង្គភាពនានាចំណុះក្រសួងមហាផ្ទៃយ៉ាងតិចចំនួន២ដងក្នុងមួយឆ្នាំ ដើម្បីពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផែនការយុទ្ធសាស្ត្រក្រសួង ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពនីមួយៗ។

អង្គភាពប្រតិបត្តិនីមួយៗត្រូវរៀបចំការតាមដានត្រួតពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំរបស់ខ្លួន។

### ៤.៣. ការវាយតម្លៃប្រចាំឆ្នាំ

នៅដំណាច់ឆ្នាំនីមួយៗ អគ្គលេខាធិការដ្ឋានត្រូវដឹកនាំ និងសម្របសម្រួលលើការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងមហាផ្ទៃ ដោយមានការចូលរួមពីគ្រប់អង្គភាពចំណុះក្រសួងមហាផ្ទៃ។ ការវាយតម្លៃនេះ ត្រូវផ្តោតលើសមិទ្ធផលសំខាន់ៗ (សកម្មភាពជាអាទិភាព សូចនាករ និងចំណុចដៅ)ដែលសម្រេចបានក្នុងឆ្នាំនីមួយៗ រួមទាំងបញ្ហាប្រឈម និងមេរៀនបទពិសោធន៍ដែលជួបប្រទះ និងទទួលបាន។ លទ្ធផលនៃការវាយតម្លៃនេះត្រូវរៀបចំដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។

### ៨.៤. ការវាយតម្លៃចុងបញ្ចប់នៃផែនការយុទ្ធសាស្ត្រ

ការវាយតម្លៃចុងបញ្ចប់ផែនការត្រូវអនុវត្តនៅចុងឆ្នាំ២០២៨ ឬដើមឆ្នាំ២០២៩ ដើម្បីពិនិត្យមើល ការសម្រេចបានសមិទ្ធផលនានា ដែលបានកំណត់នៅក្នុងតារាងសូចនាករ និងចំណុចដៅនៃផែនការយុទ្ធសាស្ត្រសម្រាប់ជាមូលដ្ឋានរៀបចំផែនការយុទ្ធសាស្ត្រដំណាក់កាលបន្ទាប់។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងដោយផ្តោតលើការសម្រេចបាននូវសូចនាករនានាដែលបានកំណត់ក្នុងតារាងសូចនាករ និងចំណុចដៅនៃផែនការយុទ្ធសាស្ត្រ រួមទាំងការសម្រេចគោលដៅ គោលបំណង និងចក្ខុវិស័យនៃផែនការយុទ្ធសាស្ត្រ។

លទ្ធផលនៃការវាយតម្លៃនេះ ក៏នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំទិន្នន័យដើមគ្រានៃផែនការយុទ្ធសាស្ត្រដំណាក់កាលបន្ទាប់។

## ៩. សេចក្តីសន្និដ្ឋាន

ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ គឺជាបុរេលក្ខខណ្ឌ និងជាបរិស្ថានគ្របដណ្តប់ ដើម្បីធានាការសម្រេចបាននូវចំណុចជាអាទិភាពនានានៃកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាល និងការរួមចំណែកដល់ការកសាងជាតិ និងការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព។

ផែនការយុទ្ធសាស្ត្រសម្រាប់វិស័យសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងគ្រប់គ្រងដែនដីក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ក្រសួងក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ ដើម្បីដឹកនាំ និងគ្រប់គ្រងរដ្ឋបាលដែនដីគ្រប់ថ្នាក់ លើកកម្ពស់ និងរក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងព្រះរាជាណាចក្រកម្ពុជា។ ផែនការនេះផ្តោតជាសំខាន់លើការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ការអភិវឌ្ឍស្ថាប័ននិងធនធានមនុស្ស ការពង្រឹងការ

ប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ។ អាស្រ័យហេតុនេះ អង្គភាពចំណុះទាំងអស់ត្រូវយកចិត្តទុកដាក់ និងចូលរួមឱ្យបានសកម្មក្នុងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងវិភាជថវិការបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងមហាផ្ទៃឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលបានជោគជ័យ។ ជាមួយគ្នានេះដែរ ការពង្រឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងការគ្រប់គ្រងដែនដី គឺជាកិច្ចការដែលត្រូវចូលរួម និងអនុវត្តដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។ អាស្រ័យហេតុនេះ ក្រសួងមហាផ្ទៃ នឹងបន្តពង្រឹងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធជាមួយស្ថាប័នទាំងនេះ ដើម្បីពង្រឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងការគ្រប់គ្រងដែនដីឱ្យកាន់តែមានប្រសិទ្ធភាព។

ក្រសួងមហាផ្ទៃមានជំនឿជឿជាក់ថា ផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ នឹងសម្រេចបានលទ្ធផលនានាតាមការគ្រោងទុក ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច សំដៅបង្កើនល្បឿនក្នុងការកាត់បន្ថយភាពក្រីក្រ និងរួមចំណែកអនុវត្តដោយជោគជ័យនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឈានទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០៕

# ផែនការយុទ្ធសាស្ត្រក្រសួងមហាផ្ទៃឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល



## ឧបសម្ព័ន្ធ៖ តារាងសូចនាករួម

| ល.រ. | សូចនាករ | ដើមគ្រា | ចំណុចដៅ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| **យុទ្ធសាស្ត្រទី១៖ ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | | | | | |
| ១ | ការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលខេត្ត | | សិក្សា | អនុម័តរបាយការណ៍សិក្សា | រៀបចំលិខិតគតិយុត្ត | អនុវត្ត | អនុវត្ត |
| ២ | ការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងមុខងាររដ្ឋបាលរាជធានី | | | សិក្សា | សិក្សា | អនុម័តរបាយការណ៍សិក្សា | រៀបចំលិខិតគតិយុត្ត |
| ៣ | ការធ្វើទំនើបកម្មប្រព័ន្ធផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | រាជធានី ខេត្ត | | ក្រុង ស្រុក ខណ្ឌ | | |
| ៤ | ចំនួនរដ្ឋបាលឃុំ សង្កាត់ដែលអនុវត្តយន្តការច្រកចេញចូលតែមួយលើសេវាអត្តសញ្ញាណកម្ម | ២៤ | ៥០០ | ១.០០០ | ១.៦៥២ | | |
| ៥ | ការវាយតម្លៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើសមិទ្ធកម្ម | | | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ៦ | ចំនួនបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទទួលការបណ្តុះបណ្តាលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន | ៧០០ | ៧៥០ | ៨៥០ | ១១០០ | ១៥០០ | ២០០០ |
| ៧ | ភាគរយនៃបណ្តឹងតវ៉ាបានសម្រុះសម្រួលដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋ | ៩១% | ៩២% | ៩៣% | ៩៤% | ៩៥% | ៩៥% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | ភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកើនឡើង | | ទិន្នន័យដើមគ្រា | | ៥% | | ៥% |
| យុទ្ធសាស្ត្រទី២៖ ការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម | | | | | | | |
| ១ | ការរក្សាការពារបានអធិបតេយ្យជាតិ បូរណភាពទឹកដី និងរាល់បញ្ហាដែលកើតឡើងតាមតំបន់ព្រំដែនបានដោះស្រាយដោយសន្តិវិធី គ្មានជម្លោះប្រដាប់អាវុធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ២ | ការពារសន្តិសុខជាតិ និងធានាសុវត្ថិភាពទាំងស្រុងនូវគោលដៅនយោបាយ ការទូត សេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ និងស្ថាប័នកំពូលៗរបស់ជាតិ ព្រះរាជសុវត្ថិភាពព្រះមហាក្សត្រ ឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ព្រមទាំងព្រឹត្តិការណ៍ជាតិ-អន្តរជាតិ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៣ | ចំនួនបទល្មើសព្រហ្មទណ្ឌកើតឡើងក្នុងចំនួនប្រជាជន ១០ម៉ឺននាក់ | ២២ លើក | ២០លើក | ២០លើក | ២០លើក | ២០លើក | ២០លើក |
| ៤ | ភាគរយនៃការបង្ក្រាបបទល្មើសព្រហ្មទណ្ឌធៀបនឹងបទល្មើសដែលបានកើតឡើងក្នុងឆ្នាំនីមួយៗ | ៩០% | ៨០-៩០% | ៨០-៩០% | ៨០-៩០% | ៨០-៩០% | ៨០-៩០% |
| ៥ | ចំនួនឃុំ-សង្កាត់មានសុវត្ថិភាពគ្មានបទល្មើសព្រហ្មទណ្ឌ | ៦០៥ | ៦២៣ | ៦៤១ | ៦៥៩ | ៦៧៧ | ៦៩៥ |
| ៦ | ការបង្ការ ការទប់ស្កាត់ និងការបង្ក្រាបអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទបានទាន់ពេលវេលា | | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍មានការថយចុះ (យ៉ាងច្រើន៤នាក់ក្នុងមួយថ្ងៃ) | ១.៥៩០នាក់ | យ៉ាងច្រើន ១៤៦០នាក់ | យ៉ាងច្រើន ១៤៦០នាក់ | យ៉ាងច្រើន ១៤៦០នាក់ | យ៉ាងច្រើន ១៤៦០នាក់ | យ៉ាងច្រើន ១៤៦០នាក់ |
| ៨ | ចំនួនប៉ុស្តិ៍នគរបាលរដ្ឋបាលដែលបានជួសជុល និងសាងសង់ថ្មី | | | ១០០ | ១០០ | ១០០ | ១០០ |
| ៩ | ការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ និងសុវត្ថិភាពល្អប្រសើរ | | ✓ | | | ✓ | ✓ |
| ១០ | ចំនួនអ្នកយល់ដឹងអំពីបញ្ហាគ្រឿងញៀនក្នុងចំណោមជនគោលដៅ និងសាធារណជនកើនឡើង | | រៀបចំទិន្នន័យដើមគ្រា | ៥% | ៥% | ៥% | ៥% |
| ១១ | ចំនួនភូមិអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ សគ្មានគ្រឿងញៀន | សាកល្បង៥ភូមិ | ភូមិយ៉ាងតិចចំនួន២នៃខេត្តជាប់ព្រំដែន | ភូមិយ៉ាងតិចចំនួន២នៃខេត្តជាប់ព្រំដែន | ចំនួនភូមិទាំងអស់នៃខេត្តជាប់ព្រំដែន | ៥០%នៃចំនួនភូមិទូទាំងប្រទេស | ភូមិទូទាំងប្រទេស |
| ១២ | ភាគរយនៃឃុំ សង្កាត់ដែលទទួលបានចំណាត់ថ្នាក់លេខ១ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព | ៦៧% | ៧០% | ៧៣% | ៧៦% | ៧៩% | ៨២% |
| ១៣ | ភាពពេញចិត្តរបស់អ្នកដំណើរចេញ ចូលនៅតាមច្រកទ្វារអន្តរជាតិ និងព្រំដែនអន្តរជាតិចំពោះការផ្តល់សេវាអន្តោប្រវេសន៍កើនឡើង | គ្មាន | រៀបចំទិន្នន័យដើមគ្រា | ៥% | ៥% | ៥% | ៥% |
| ១៤ | អត្រាជនបរទេសជ្រៀតចូលស្នាក់នៅ និងប្រកបការងារខុសច្បាប់ថយចុះ | ០,០៥% | <០,០៥% | <០,០៥% | <០,០៥% | <០,០៥% | <០,០៥% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៥ | ភាគរយជនបរទេសដែលមានវត្តមាននៅកម្ពុជាបានគ្រប់គ្រង និងកត់ត្រាក្នុងប្រព័ន្ធទិន្នន័យអន្តោប្រវេសន៍ | ៩០% | ៩០% | | ៩៥% | | ៩៨% |
| **យុទ្ធសាស្ត្រទី៧៖ ការលើកកម្ពស់ការគ្រប់គ្រងពន្ធនាគារ** | | | | | | | |
| ១ | ការកែសម្រួលនីតិវិធី និងស្តង់ដានៃការគ្រប់គ្រងពន្ធនាគារ | | អនុម័ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ២ | ភាគរយជនជាប់ឃុំបានទទួលសេវាជំនួយផ្នែកច្បាប់ និងសេវាព័ត៌មាន | | ៦៥% | ៧០% | ៧៥% | ៨០% | ៨៥% |
| ៣ | ភាគរយជនជាប់ឃុំទទួលសេវាពិនិត្យ និងថែទាំសុខភាព | ៨៥% | ៨៧% | ៨៩% | ៩១% | ៩៣% | ៩៥% |
| ៤ | ភាគរយនៃជនជាប់ឃុំបានចូលរួមអនុវត្តកម្មវិធីអប់រំរៀនសូត្រ | ៦៧% | ៧១% | ៧៥% | ៧៨% | ៨១% | ៨២% |
| ៥ | ភាគរយទណ្ឌិតដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ និងមានការបញ្ជាក់ពីលទ្ធផលនៃការសិក្សា | ៣៤% | ៣៦% | ៣៨% | ៤០% | ៤២% | ៤៤% |
| ៦ | ភាគរយជនជាប់ឃុំទទួលបានសេវាព្យាបាលផ្លូវចិត្ត និងផលប៉ះពាល់គ្រឿងញៀន គ្រឿងស្រវឹង | ៧០% | ៧៥% | ៨០% | ៨៥% | ៩០% | ៩៥% |
| ៧ | ចំនួនពន្ធនាគារបានដំណើរការសិប្បកម្ម | ១៦ | ១៩ | ២២ | ២៤ | ២៥ | ២៩ |
| **យុទ្ធសាស្ត្រទី៩៖ ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស** | | | | | | | |
| ១ | ការវិភាគមុខងារ និងការសិក្សាអំពីតម្រូវការធនធាន | | របាយការណ៍ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | មនុស្សឆ្លើយតបទៅនឹងរចនាសម្ព័ន្ធ និងទំហំការងាររបស់អង្គភាពនីមួយៗ | | សិក្សា | | | | |
| ២ | ការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់អង្គភាពនីមួយៗ និងលក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗ | | ការសិក្សា | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ៣ | ការរៀបចំ និងកែសម្រួលក្រមសីលធម៌វិជ្ជាជីវៈ និងវិន័យការងារ | | អនុម័ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ៤ | ការវាយតម្លៃបុគ្គលិកផ្អែកលើសមិទ្ធកម្ម | | រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ៥ | ចំនួនថ្នាក់ដឹកនាំអង្គភាពចាប់ពីអនុប្រធានការិយាល័យឡើងទទួលបានការបណ្តុះបណ្តាលពីសាលាជាតិរដ្ឋបាលមូលដ្ឋាន | ១៥០ | ១៥០ | ២០០ | ២៥០ | ៦៥០ | ៦៥០ |
| ៦ | ចំនួនមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃទទួលបានការបណ្តុះបណ្តាលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន | ១០០ | ១០០ | ១៥០ | ២០០ | ២០០ | ២០០ |
| ៧ | ចំនួនមន្ត្រីជាស្ត្រីទទួលបានការបណ្តុះបណ្តាលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន | ៨០ | ៩០ | ១២០ | ១៥០ | ២០០ | ២០០ |
| ៨ | ការសាងសង់សាលាជាតិរដ្ឋបាលមូលដ្ឋាន | | ចាប់ផ្តើម | បញ្ចប់ | | | |
| ៩ | ចំនួនគម្រោងស្រាវជ្រាវអំពីអភិបាលកិច្ចមូលដ្ឋាន | ២ | ២ | ២ | ៣ | ៣ | ៣ |
| ១០ | ការពិនិត្យកែលម្អផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងមហាផ្ទៃ និងថវិកាសមិទ្ធកម្ម | ១លើក | ២លើក | ២លើក | ២លើក | ២លើក | ២លើក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១ | ការបង្កើតយន្តការពិនិត្យ និងតាមដានលើការអនុវត្តការងារភស្តុភារ គណនេយ្យ ហិរញ្ញវត្ថុ និងគ្រប់គ្រងចំណូល ចំណាយ | | | សិក្សា | អនុវត្ត | អនុវត្ត | អនុវត្ត |
| ១២ | ការរៀបចំមណ្ឌលអភិវឌ្ឍចំណេះដឹងអំពីការអភិវឌ្ឍមូលដ្ឋាន | 0% | ១0% | ៣0% | ៥0% | ៧៥% | ១00% |
| ១៣ | ចំនួនអង្គភាពផ្នែករដ្ឋបាលស៊ីវិលចំណុះក្រសួងមហាផ្ទៃទទួលរងសវនកម្មផ្ទៃក្នុង | ១៧៥ | ១៧៨ | ១៨៥ | ១៨៨ | ១៩0 | ២00 |
| ១៤ | ចំនួនអង្គភាពផ្នែកសន្តិសុខសាធារណៈចំណុះក្រសួងមហាផ្ទៃទទួលរងសវនកម្មផ្ទៃក្នុង | ៨៥0 | ៩៥0 | ១0៥0 | ១0៥0 | ១0៥0 | ១0៥0 |
| ១៥ | ចំនួនអង្គភាពផ្នែកពន្ធនាគារចំណុះក្រសួងមហាផ្ទៃទទួលរងសវនកម្មផ្ទៃក្នុង | ៣៤ | ៣៤ | ៣៤ | ៣៤ | ៣៤ | ៣៤ |
| ១៦ | ភាគរយនៃបណ្តឹងសរុបក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រសួងមហាផ្ទៃត្រូវបានដោះស្រាយ | ៨៥% | ៨៥% | ៨៧% | ៨៧% | ៩0% | ៩៥% |
| ១៧ | ចំនួននិស្សិតថ្នាក់បណ្ឌិត ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រនគរបាល និងថ្នាក់បរិញ្ញាបត្រពន្ធនាគារទទួលបានការបណ្តុះបណ្តាលនៅបណ្ឌិត្យសភានគរបាលកម្ពុជា | ៩៦៤ | ៣២0 | ៣២0 | ៣២0 | ៣២0 | ៣២0 |
| ១៨ | ចំនួននិស្សិតថ្នាក់សញ្ញាបត្រមធ្យមឯកទេសនគរបាល សិក្សារយៈពេល២ឆ្នាំ និងថ្នាក់វិញ្ញាបនបត្រ ជាន់ខ្ពស់ជំនាញនគរបាល សិក្សារយៈពេល១ឆ្នាំ ទទួលបានការ | គ្មាន | ៤00 | ៤00 | ៤00 | ៤00 | ៤00 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | បណ្តុះបណ្តាលនៅបណ្ឌិត្យសភានគរបាលកម្ពុជា | | | | | | |
| ១៩ | ចំនួនថ្នាក់ដឹកនាំ មន្ត្រីនគរបាល និងមន្ត្រីពន្ធនាគារទទួលការបណ្តុះបណ្តាលបំប៉នជំនាញឯកទេសក្នុងវគ្គសិក្សាខ្លីៗ(១ខែដល់៦ខែ) នៅបណ្ឌិត្យសភានគរបាលកម្ពុជា | គ្មាន | ២៥០០ | ២៦០០ | ២៧០០ | ២៨០០ | ២៩០០ |
| ២០ | ចំនួនសិស្សនគរបាលជ្រើសរើសថ្មីទទួលបានការបណ្តុះបណ្តាលនៅបណ្ឌិត្យសភានគរបាលកម្ពុជា | គ្មាន | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ | ២៥០០ |
| ២១ | ចំនួនគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រលើការងារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសង្គម ពន្ធនាគារ និងការងារពាក់ព័ន្ធដែលត្រូវធ្វើការសិក្សាស្រាវជ្រាវ | ២ | ២ | ២ | ២ | ២ | ២ |
| ២២ | ការបន្តអភិវឌ្ឍធនធានរូបវន្ត និងបំពាក់ធនធានសិក្សារបស់បណ្ឌិត្យសភានគរបាលកម្ពុជា | ២០% | ៣០% | ៤៥% | ៦០% | ៨០% | ១០០% |
| **យុទ្ធសាស្ត្រទី៥៖ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ** | | | | | | | |
| ១ | ការចុះបញ្ជីអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ និងបញ្ជីអត្តសញ្ញាណកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Online) | សាកល្បង | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ២ | ការបំពាក់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យអ្នកដំណើរចូល ចេញឆ្លងកាត់នៅគ្រប់ច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារព្រំដែនទ្វេរភាគី | គ្មាន | ២០% | ៣០% | ៤០% | ៥០% | ៦០% |
| ៣ | ការអភិវឌ្ឍ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាអន្តោប្រវេសន៍ | | | | | រៀបចំ | អនុវត្ត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | ការចុះបញ្ជីគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងសមាគមតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល | | រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ៥ | ភាពពេញចិត្តនៃការផ្ដល់សេវារដ្ឋបាលក្នុងក្របខ័ណ្ឌសមត្ថកិច្ចក្រសួងមហាផ្ទៃ | គ្មាន | | រៀបចំទិន្នន័យដើមគ្រា | | | កើនឡើង ១០% |
| ៦ | ចំនួនតិលានដ្ឋានសម្រាប់ស្ទង់ការដ្ឋាននគរបាលរាជធានី-ខេត្ត | ១ | 0 | ១ | ១ | ២ | ២ |
| ៧ | ចំនួនអ្នកទទួលសេវាសុខាភិបាលដែលផ្ដល់ដោយសមត្ថកិច្ចក្រសួងមហាផ្ទៃកើនឡើង | ៩៤៧៥ នាក់ | ១០% | ១៥% | ១៥% | ២០% | ២០% |
| **យុទ្ធសាស្ត្រទី៦៖ ការងារបច្ចេកវិទ្យាឌីជីថល** | | | | | | | |
| ១ | ម៉ាស៊ីនមេ និងប្រព័ន្ធបច្ចេកវិទ្យារបស់អង្គភាពចំណុះក្រសួងមហាផ្ទៃត្រូវផ្លាស់ប្ដូរទីតាំង ឬបញ្ចូលមកក្នុងមជ្ឈមណ្ឌលទិន្នន័យ (Data Center) ក្រសួងមហាផ្ទៃ | ១០% | ៣០% | ៥០% | ៧០% | ៩០% | ១០០% |
| ២ | ការរៀបចំថ្នាលផ្លាស់ប្ដូរទិន្នន័យរបស់ក្រសួងមហាផ្ទៃសម្រាប់ផ្លាស់ប្ដូរទិន្នន័យរវាងអង្គភាពចំណុះ និងជាច្រកចេញចូលតែមួយសម្រាប់ផ្លាស់ប្ដូរទិន្នន័យជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ | 0 | ៥% | ២០% | ៥០% | ៨០% | ១០០% |
| ៣ | ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន រវាងអង្គភាពក្រោមចំណុះថ្នាក់ជាតិ និងពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ក្របខ័ណ្ឌក្រសួងមហាផ្ទៃ | ១០% | ២០% | ៤០% | ៦០% | ៨០% | ១០០% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | ការរៀបចំមជ្ឈមណ្ឌលការពារសុវត្ថិភាពបច្ចេកវិទ្យាឌីជីថល (SOC) បម្រើការងារស្រាវជ្រាវ តាមដានវិភាគទិន្នន័យ និងការពារសុវត្ថិភាព ប្រព័ន្ធបច្ចេកវិទ្យាក្របខ័ណ្ឌក្រសួងមហាផ្ទៃ | | | រៀបចំ | ដំណើរការ | ដំណើរការ | ដំណើរការ |
| ៥ | គោលនយោបាយ និងបទដ្ឋានយុទ្ធសាស្ត្រសុវត្ថិភាពបច្ចេកវិទ្យាឌីជីថលក្របខ័ណ្ឌក្រសួងមហាផ្ទៃ | | | រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត |
| ៦ | ការបំពាក់កាមេរ៉ាវៃឆ្លាតបម្រើការងារចរាចរណ៍ សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈទូទាំងរាជធានី ខេត្ត | | ២០% | ២០% | ២០% | ២០% | ២០% |
| ៧ | គោលនយោបាយ បទដ្ឋានយុទ្ធសាស្ត្រវាយតម្លៃ និងប្រឹក្សាយោបល់សុវត្ថិភាពបច្ចេកវិទ្យាឌីជីថលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ | | | រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត |
| ៨ | ប្រព័ន្ធកម្មវិធីជំនួយបន្ទាន់ក្រសួងមហាផ្ទៃ សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងប្រទេសកម្ពុជា (Web and Application) | | រៀបចំ | ដំណើរការ | ដំណើរការ | ដំណើរការ | ដំណើរការ |
| ៩ | ប្រព័ន្ធទទួលពាក្យបណ្តឹង និងគ្រប់គ្រងសំណុំរឿងសន្តិសុខសាធារណៈបច្ចេកវិទ្យាឌីជីថល | | | រៀបចំ | ដំណើរការ | ដំណើរការ | ដំណើរការ |
| ១០ | ការរៀបចំយន្តការវាយតម្លៃសមត្ថភាពមន្ត្រីពាក់ព័ន្ធនឹងការយល់ដឹងអំពីឌីជីថល | | | រៀបចំ | អនុវត្ត | | អនុវត្ត |
| ១១ | ចំនួនវគ្គបណ្តុះបណ្តាលមូលធនមនុស្សឌីជីថល និងការផ្សព្វផ្សាយអប់រំបញ្ញាបចំណេះដឹងអំពីហានិភ័យ | ១៤វគ្គ | ២០វគ្គ | ២០វគ្គ | ២០វគ្គ | ២០វគ្គ | ២០វគ្គ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | នៃបទល្មើសបច្ចេកវិទ្យា និងការបង្ការទប់ស្កាត់បទល្មើសបច្ចេកវិទ្យា | | | | | | |
| ១២ | ប្រព័ន្ធទិន្នន័យអនឡាញក្នុងការគ្រប់គ្រងព័ត៌មានគណបក្សនយោបាយ អង្គការសង្គមស៊ីវិល និងសមាគម | | រៀបចំ | ដំណើរការ | ដំណើរការ | ដំណើរការ | ដំណើរការ |
| ១៣ | ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារដោយប្រើបច្ចេកវិទ្យាទំនើប | | រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត |
| ១៤ | ការបង្កើតមជ្ឈមណ្ឌលទិន្នន័យទំនើប និងមានសុវត្ថិភាពសម្រាប់ប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជន | | រៀបចំ | បន្តរៀបចំ | បន្តរៀបចំ | ដំណើរការ | ដំណើរការ |

**ចក្ខុវិស័យ៖**

រដ្ឋបាលដែនដីនៅគ្រប់ថ្នាក់
ជាដៃគូរបស់ប្រជាជន លើកកម្ពស់ជីវភាពប្រជាជន បម្រើសេវា
និងការពារផលប្រយោជន៍ប្រជាជន តាមគោលការណ៍អភិបាលកិច្ចល្អ
និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប្រទេសជាតិមានសុខសន្តិភាព សន្តិសុខ
សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជាមូលដ្ឋានគ្រឹះចាំបាច់សម្រាប់ការអភិវឌ្ឍ
ប្រទេសជាតិលើគ្រប់វិស័យ ប្រជាជនមានសិទ្ធិសេរីភាព មានជីវភាពរស់នៅល្អប្រសើរ
និងការរស់នៅប្រកបដោយភាពសុខក្សេមក្សាន្ត។

**បេសកកម្ម៖** ការលើកកម្ពស់ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់ថ្នាក់ ព្រមទាំងការពង្រឹងសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដើម្បីឆ្លើយតបទៅនឹងតម្រូវការ សំណើសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាព គុណភាព គណនេយ្យភាព តម្លាភាព យុត្តិធម៌ បរិយាបន្ន និងសមធម៌សង្គម។

**គោលដៅ៖**
១) ការរៀបចំ និងការពង្រឹងស្ថាប័នក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
២) ការពង្រឹងប្រសិទ្ធភាពនៃការបំពេញការងារ និងការទទួលខុសត្រូវរបស់មន្ត្រី
៣) ការពង្រឹង និងការកែលម្អយន្តការ និងនីតិវិធីផ្តល់សេវាសាធារណៈ ។

**យុទ្ធសាស្ត្រ ទី១**
ការពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ

**យុទ្ធសាស្ត្រ ទី២**
ការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម

**យុទ្ធសាស្ត្រ ទី៣**
ការលើកកម្ពស់ការគ្រប់គ្រងពន្ធនាគារ

**យុទ្ធសាស្ត្រ ទី៤**
ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស

**យុទ្ធសាស្ត្រ ទី៥**
ការលើកកម្ពស់ការផ្តល់សេវាសាធារណៈក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ

**យុទ្ធសាស្ត្រ ទី៦**
ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល

អភិក្រម: ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់


អគារ ២៧៥ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ក្រសួងមហាផ្ទៃ
Ministry of interior Cambodia

interior.gov.kh

info@interior.gov.kh


ស្កេនដើម្បីទាញយកឯកសារផែនការយុទ្ធសាស្ត្រ